ភម្ពសទិយា

ទស្សនាវិដ្ឋី ផ្សាយដំណឹងទាងសាសនា នឹងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ៩



INSTITUT BOUDDHIQUE

ក្នុងពេញ

ការផ្សាយរបស់ព្រះភាគបណ្ណាល័យ

ព.ស. ២៤៨៤

ឌ.ស.១៩៤១

L
ស:09

ព្រះរាជបណ្ណាល័យកម្ពុជា

KAMBUJASURIYÂ

កម្ពុជសុរិយា

ជាទស្សនាវដ្ដីបោះពុម្ពាយពីព្រះរាជបណ្ណាល័យ មួយរៃពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ៩

គណៈរដ្ឋមន្ត្រីនឹងសម្តេចសង្ឆនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ក្នុំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស.១៩៤១

បញ្ជីរឿង

ទំព័រ

១ — ការស្រង់យកសេចក្តីខ្ទះអំពីសៀវភៅនិយាយអំពីអារ្យធមិរបស់ឥណ្ឌៀ ៣

២ — សេចក្តីស្រង់អំពីរឿងមួយនិយាយអំពីការសិក្សា ជាសេចក្តីអធិប្បាយដោយ
សង្ខេបរបស់ ត. ប. ដេម៉ារកែត្តឺ ៨

៣ — អំពីពង្សាវតារក្រិក រួបរួមអំពីគោលចារិកផ្សេងៗ ក្នុងពង្សាវតារលោក(តមក).. ១៤

៤ — ប្រជុំពាក្យកាព្យខ្មែរ ភាគទី ៤ របស់ឃុនស៊ីមនោម៉យ (តមកពីទស្សនាវដ្តីលេខ
១២ ឆ្នាំ ១៩៤០) ១៣

៥ — អនាមយកថា របស់ទេមររង្សី (តមក) ២២

៦ — រឿងព្រេងខ្មែរ: "រឿងអាឡេវទី ២" របស់អ្នកឧកញ៉ាប្រាជ្ញាធំបតី យិន
(តមក). ២៥

រួបក្រោរឿង

សាមនៀ (ប្រទេសលាវ) ភូមិបានថន ត្រូសារត្រកូលក្យ៉ ១

TABLE DES MATIÈRES

Pages.

1° Quelques notes au sujet d'un livre sur l'Inde civilisatrice... 3

2° Extrait d'un article sur l'éducation par G. C. Démarquette.. 8

3° Histoire de la Grèce, extrait de divers documents de l'Histoire Universelle (suite)..... 14

4° Recueil des poèmes cambodgiens 4e partie par KHUN SIMANOMAY (suite de la revue n° 12 du 1940)..... 17

5° ANĀMAYAKATHĀ par KHÉMARARANSĪ (suite)..... 22

6° Conte populaire cambodgien inédit :

" Légende de ALÉV II " par Oknhā PRACHNHĀTHĪBADEY (YIN) (suite)..... 25

HORS TEXTES :

Sam neua (Laos) — la famille du PHYA..... 1

សាមុនើ្យ ឫទេសណៃ - ភូមិបាងជន ត្រូសាត្រកូលភ្សា ។

អារ្យធម៌របស់ឥណ្ឌៀ

ផែនទីភូមិសាស្ត្ររបស់ប៉្តូលេម៉េ(១) (Ptolémée) កាលពីពុទ្ធសករាជ ៦៩៣ នោះលោកប៉្តូលេម៉េបានអធិប្បាយពីចំណេះវិជ្ជារបស់ឥណ្ឌៀ កាលសម័យបុរាណនោះថាជាចំណេះខ្ពង់ខ្ពស់ណាស់ ៗ ប៉ុន្តែផែនទីឥណ្ឌៀ ដែលលោកប៉្តូលេម៉េធ្វើទុកមកនោះធ្វើដោយស្មានៗមិនទាន់ពិតប្រាកដដូច ផែនទីសព្វថ្ងៃនេះទេ តែមានអ្វីៗសព្វគ្រប់ គឺមានសមុទ្រ, ឈូងសមុទ្រ, ទន្លេ, ស្ទឹងព្រែក, ភ្នំ, ប្រជាជន, ខេត្តដែន, ទីក្រុងនិងអ្វីៗទៀតច្រើន ស្មុគស្មុះ ៗ យើងអាចនឹងបានឃើញរឿងខ្លះនោះ មានជាប់នៅនឹង ពង្សាវតាររបស់ឥណ្ឌៀ ហើយមាននៅនឹងអនុស្សាវរីយ៍ ដែលកសាង ឡើងតាមវិជ្ជាការរបស់ក្រិក ៗ តាមទំនងនេះ ដោយសារតែសៀវភៅឬ ផែនទីរបស់លោកប៉្តូលេម៉េនេះហើយ ដែលធ្វើឲ្យយើងបានដឹងស្គាល់អារ្យធម៌របស់ហិណ្ឌូនោះ ផ្សាយចេញទៅយ៉ាងធំទូលាយ ហើយចូលមកក្នុង ប្រទេសឥណ្ឌូស៊ីននិងបណ្តាប្រទេសអាំងស៊ុយឡាំងទ៍ (Insulinde) មាត់ សមុទ្រនៃប្រទេសប៉េគូ ជ្រោយប្រទេសមលូកា តាមមាត់សមុទ្រអស់នេះ

---

(១) ជាអ្នកប្រាជ្ញជាតិក្រិកនៅក្នុងស្រុកអាលេក្សង់ឌ្រី ជាអ្នកយកចិត្តទុកដាក់នឹងវិទ្យាសាស្ត្រ មានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងប្រទេសអារ៉ាប់ លោកបានរួបរួមចំណេះវិជ្ជាជាន់ចាស់ចំណែកខាង វិជ្ជាហោរាសាស្ត្រ ជាអ្នកចេះដឹងខាងធម៌ វិជ្ជាលេខទព្វន្តនិងភ្លេង, កាព្យឃ្លោងនិងវិជ្ជាហ្វ៊ីស៊ិកជាដើម ។ ក្នុងវចនានុក្រមឡារូសនិយាយថា ថ្វីដៃរបស់លោកនេះមានច្រើនណាស់ គឺបានតែង វិជ្ជាតារាសាស្ត្រ ប្រវត្តិសាស្ត្រ លេខ, ភូមិសាស្ត្រនិងវិជ្ជាភ្លេងជាដើម ។

សុទ្ធតែជាទីតាំងផ្ទះដំនួញជាតិហិណ្ឌូ ដូចជាប្រទេសវ៉ាក៏មានពួកហិណ្ឌូ
ទៅតាំងនៅដែរ ហើយមន្ទីរដំនួញដែលបានឃើញនៅជាន់ក្រោយ ១ នោះ
តាមសៀវភៅលោកប្ហ្លូ លេម៉ូ ថាមាននៅលើផែនដីចំណែកអស់នេះ ។

ផ្ទះសម្ដេចនោះហើយធ្វើឲ្យជនជាតិផ្សេងៗកាន់តែជិតគ្នាឡើងហើយ
ក៏តមានកំពង់ដំនួញឡើង ដែលមានដំនួញរបស់ជាតិក្រិកតែងចេញចូល
រឿយ ១ ។ ត្រានោះមានជាតិក្រិកអាពុតនឹងកូនឈ្មោះ ឆម្ការ ក្ដិត មាន
សទ្ធាជ្រះថ្លានឹងគណៈសង្ឆក្នុងព្រះពុទ្ធសាសនា ហើយបានកសាងគុហា ១
ចេតិយ ១ ទីដ៏អណ្ដូងទ ១ ជាច្រើន ដើម្បីជាគ្រឿងសក្ការៈបូជាដល់ព្រះពុទ្ធ
ទាំងឡាយ ។ មានជាតិក្រិកម្នាក់ទៀតនោះ បូជាអណ្ដូងទ ១ ជាច្រើន មាន
ជាតិក្រិកម្នាក់ទៀតកសាងកេងមាន ១ បូជាព្រះដែរ ប៉ុន្ដែគុហាទាំងនោះគេ
ប្រដាប់តាក់តែងរចនាជារបៀប ១ របស់ក្រិក-ឥណ្ឌូ មិនមែនដូចជាគុហា
ធម្មជាតិនៅប្រទេសមគធ:នោះឡើយ គឺជាផលនៃសិល្បកម្ម ដូចជានៅ
ការលី សំដ៏មានក្បាច់ចម្លាក់យ៉ាងល្អ ១ ដូចជានៅព្រះស្ដូបអមរាវតី សំដ៏ប្រ-
ដាប់ប្រដាដោយគ្រឿងចម្លាក់ផ្សេង ១ ជាអនេក ។ ផ្ទះនៃសេចក្ដីចំរើន
ដ៏ធំធ្ងន់ យ៉ាងរបស់លោកនោះ បានចាប់ចូលទៅកាន់ប្រទេសឥណ្ឌូ យ៉ាងជ្រៃ
ជ្រៃ ១ ១ តាំងពីយូរមកហើយ ឥឡូវនេះអារ្យធម្មនោះមិនបានបំបាត់ចប់
ស្ងួតទាំងដើមទៅទេ ប៉ុន្ដែប្រទេសជិតខាងក្ដី អ្នកដែលមកជណ្ដើមយក

ទៅក្តី សឹងយកទៅកែប្រែធ្វើឲ្យបានចំរើនល្អឡើងជាចំណែក ១ ដោយខ្មែរ ៗ

តាមដោយពិតនោះ នៅក្នុងសម័យនីមួយៗនោះ តាមពង្សាវតារដ៏វែងឆ្ងាយ ប្រទេសឥណ្ឌាមិនទាន់បានស្គាល់សេចក្តីចំរើនរុងរឿង និងការរុករកយ៉ាងម៉ឺងម៉ាត់ដូចនៅក្នុងចន្លោះជំនៃពុទ្ធសករាជ ៨៤៣ និង ៩៤៣ នោះឡើយ គឺតាំងពីរាជវង្សក្សត្រិយ៍គុប្ត: បានរៀបចំកសាងមហាអាណាចក្រឡើង ហើយចាត់ចែងការពារនិងបណ្ដុះបណ្ដាលវិជ្ជាអក្សរសាស្ត្រនិងរបៀបវេទនាឲ្យចំរើនឡើង ៗ បឋមក្សត្រិយ៍នៃរាជវង្សនេះទ្រង់ព្រះនាមចន្ទ្រគុប្ត: ទ្រង់អភិសេកនឹងក្សត្រី ១ អង្គទ្រង់ព្រះនាមកុមារទេវី ជារាជវង្សនៃពួកក្សត្រិយ៍លិច្ឆវី កាលពីសម័យពុទ្ធកាលនោះ ពួកក្សត្រិយ៍អស់នេះបានរៀបចំរាជការដោយសាមគ្គីធម៌ ធ្វើឲ្យក្រុងវេសាលីនេះចំរើនសុខស្ដុកស្ដម្ភណាស់ ៗ

ព្រះបាទចន្ទ្រគុប្ត:ទ្រង់ឲ្យបោះពុម្ពប្រាក់រៀលដោយមាស ដែលមានរូបទ្រង់នឹងរូបអគ្គមហេសីជាប់នៅនឹងប្រាក់រៀលនោះ ៗ

ប្រហែលក្នុងពុទ្ធសករាជ ១១៤៣ មានគណៈធម្មទូត ១ ក្រុមមកពីស្រុកចិន ដើរធុតង្គទៅប្រទេសឥណ្ឌាដោយចិត្តសទ្ធាជ្រះថ្លា ដើម្បីទៅមើលព្រះវិហារមហាពោធិ ដែលគេបានកសាងឡើងត្រង់ទីកន្លែងដែលព្រះពុទ្ធជាម្ចាស់បានត្រាស់សព្វញ្ញុតញ្ញាណ ហើយបានឃើញវត្តមួយ

នោះមានលោកសង្ឆ្យពីកោះលង្កាមកកាន់តាបថែវក្យយ៉ាងម៉ឺងម ត់ ហើយ
គេបានស្ដាប់រកដើមកំណើតដែលបានកសាងវត្តនេះឡើង បានទទួលពាក្យ
តបដូច្នេះ "កាលពីដើមនោះ មហាក្សត្រិយ៍ប្រទេសសីឡង់ ទ្រង់ព្រះនាម
ព្រះស្រីមេឃវណ្ណ ជាស្ដេចជាតិតណ្ហ ទ្រង់ចាត់បញ្ជូនលោកសង្ឆ
ពីរូបឲ្យទៅមើលវត្ថុដែលព្រះបាទអសោកទ្រង់កសាងឡើងដោតដើមពោ-
ធិព្រឹក្សដែលព្រះពុទ្ធបានត្រាស់ដឹងនោះ វិហារធំហៅថា មហានាម៉ន
វិហារ ១ ទៀតហៅថា ឧបសេន លោកពីរូបនេះចូលទៅនមស្សការ
បល្ល័ង្ករតដ្ដ ក្រោមដើមពោធិព្រឹក្ស ប៉ុន្តែវិហារនោះសំណាក់ពុំបាន ។
លោកពីរូបត្រឡប់មកស្រុកកំណើតរបស់ខ្លួនវិញ ទើបស្ដេចមានព្រះពាជ-
ឫទ្ធារសួរថា លោកតាំងពីរូបទៅនមស្សការដល់ទីបូជនីយស្ថាន បានឮ
គេនិយាយអ្វីជាមង្គលដល់លោកខ្លះដែរឬទេ? លោកតាំងពីរូបក៏ថ្វាយព្រះ
ពរតបថា នៅស្រុកធំៗនៃជម្ពូទ្វីបនេះ មិនមានប្រទេសណាតាំងនៅកន
ន្ធិកាពទ្បើយ ។ ស្ដេចទ្រង់ព្រះសណ្ដាប់សំដីអស់នេះហើយ ទើបទ្រង់
ចាត់មនុស្សជាពជបម្រើ ឲ្យនាំយកពេជ្ជនិលចិន្ដាទៅថ្វាយស្ដេចតុ្ដ: ជា
ត្ដ្ងឹងពជបណ្ណ្ណ ។ ដោយហេតុដូចពោលមកនេះហើយ បានជាមាន
លោកសង្ឆ្យពីលង្កាទ្វីបទៅតាំងនៅប្រចាំក្នុងវិហារនេះ ។

ផ្ទៃនដ៏ពោធិតយាជាទីដែលមានសិលាចារឹក ២ អាន្ទ ដែលគេបានក
សាងទុកជាទីរាឫកដល់មហានាម៉ន មានកំណើតដើមនៅលង្កា ។ តាម

ប្រវត្តិសាស្ត្រលង្ការនិយាយថា កាលពីពុទ្ធសករាជ ៩៤៣ រហូតដល់ពុទ្ធ-
សករាជ ៦៣៤៣ មានចេញឈ្មោះស្តេច កីត៍ស្រីមេឃវណ៌ ដែលទ្រង់
សោយរាជ្យ (ក្នុងរវាងពុទ្ធសករាជ ៨៤៧ នឹង ៨៧៥) ក្សត្រិយ៍អង្គនេះជា
ស្តេចដែលទ្រង់ជ្រះថ្ថានឹងព្រះពុទ្ធសាសនាណាស់ ក្នុងរាជ្យរបស់ទ្រង់
នេះហើយដែលបានព្រះសារីរិកធាតុ គឺព្រះទន្តធាតុរបស់ព្រះពុទ្ធជាម្ចាស់
ដែលគេនាំចូលមកស្រុកសីឡង់ នាំចេញមកពីស្រុកកាលិង្គៈ នៅស្រុក
នោះគេតាំងឈ្មោះក្រុង ១ ហៅថា ទន្តបុរៈ (ដើម្បីជាកិត្តិយសដល់ព្រះ
សារីរិកធាតុនេះ) ។ ហេតុដែលបានព្រះទន្តធាតុមកលង្ការទ្វីបនេះ
ដោយមានក្សត្រីប្រទេសកាលិង្គៈ ១ អង្គ បានលបលួចយកព្រះទន្តធាតុ
នោះជាក់ក្នុងផ្ទុងសក់ (មកថ្វាយស្តេចលង្ការ) ។ ស្តេចមេឃវណ៌ ផ្ទើពិធី
ទទួលព្រះទន្តធាតុជាតទ្បាវិក ហើយហែហមយ៉ាងអិកធឹកទៅដំកល់ទុក
នៅទីវត្តដែលរៀបចំទុកដោយឡែក ។ មហាក្សត្រិយ៍អង្គនេះ ទ្រង់តែង
កាព្យ ១ ជាភាសាលង្ការ ដើម្បីជាកិត្តិយស ហៅថា ទលទារង្ស ឬប្រវត្តិ
ព្រះទន្តធាតុ ។

(នៅមាន ត).

អំពីការសិក្សាស្វែងរកសន្តិភាព ជាសេចក្តីអធិប្បាយ

ដោយសង្ខេបរបស់លោក គ. ប. ដេម៉ាវ៉ែត្ត

ច្បាប់បុរាណដែលប្រកបដោយហេតុផលដ៏ត្រឹមត្រូវនោះ តែងប្រ-
កាន់ថា កំណើតនៃធម្មជាតិឬអាការណាទីមួយ កាលបើមានឫសគល់ជា
គោលដ៏រាមកផ្ទុំប្រជុំគ្នាហើយ រមែងកើតមានសេចក្តីចំរើនឡើង ។ ឯអារ្ស-
ធម្មមិនដឹងបានតាមនៅបានក៏គោងអាស្រ័យកំឡាំងកម្មជាបច្ច័យ ឯដ្ឋយដ៏នេះ
ដ៏ខ្ជៀងតាត់នោះ កើតឡើងដោយកំឡាំងការចងចាប់ដ៏មានរបៀបបែប
ផែន ការមានមេត្រីចិត្តនឹងសាមគ្គីធម្មក្នុងរវាងមនុស្សម្នាក់ៗនឹងមនុស្ស-
ពៅ ។ ឯហេតុនៃការប្រេះឆា ចាកបែក ខ្ចប្ចាតអន្ទាយអស់នេះកើត
ឡើងដោយអំណាចនៃអត្តទិដ្ឋ (យល់តែប្រយោជន៍ខ្លួន) ទើបកើតបែក
ខ្ញែកបែកជាក្រុមជាពួកតែដោយខ្លួនៗពៅ ។ ការប្រជ័ងប្រែងចប់ចល់នឹងដ្ឋយ
ដ៏នេះក្នុងការបរិច្ចាគក្នុងសាមគ្គីធម្មមិនមានមេត្រីចិត្តនឹងតាងនៅបាន លុះត្រាតែ
លះបង់ចិត្តប្រកាន់ពួក អត្តទិដ្ឋនឹងសេចក្តីពាក្យចាកចេញ ដែលជាហេតុ
ធ្វើសេចក្តីបរិសុទ្ធិស្អ្នកនោះឲ្យប្រែត្រឡប់ពៅជារួបរួមគ្នាខាងផ្លូវអាត្ម៉ាវិញ
ដែលពោលតាមបែបអ្នកប្រាជ្ញ (ជំនាន់ថ្មី) ថា ដ្ឋយ ពិដ្ឋយ សង្ក្រាម
(ចានដល់ការចម្ការ៉ាងរ៉ាងដ)ល) ។

- ការពង្រីកអាណាចក្រដោយចម្បាំងជារបស់ប្រកបដោយកិត្តិយសដ៏ខ្ពង់ខ្ពស់ នេះជាទំនៀមរបស់មនុស្សជាតិ ហើយជាហេតុធ្វើឲ្យមនុស្សស្លូតត្រង់មានសីលធម៌ល្អកើតគំនិតគិតចង់ធ្វើជានាយកលើអ្នកដទៃ ពង្រីកអំណាចក្អេងក្អាងដូចជាលោកឆិត្ល័រ លោក រុស្សូ្លដែលស៍ ទីងលោកហ៊្សង់ឡាហារ ។ ទុកជាមានសេចក្តីព្យាយាមយ៉ាងម៉ឺងម៉ាត់ក្នុងការប្រើគំនិតទំនងនេះក៏ដោយ ក៏កម្រនឹងមានជ័យជំនះលើមនុស្សសម័យបុកណ បានលុះត្រាតែកាលណាយើងព្យាយាមកំចាត់នូវអត្តទិដ្ឋិ, និស្ស័យខ្ជិលច្រអូសទីងនិស្ស័យគ្រោតគ្រាតទាំងពួងចេញបាន ទើបយើងអាចកាន់យកនូវសន្តិភាពនឹងយុត្តិធម៌ក្នុងលោកនេះបាន ។

ជិត ២.០០០ឆ្នាំមកហើយដែលព្រះយេស៊ូបានរំឭកយើងថា កិច្ចការនានាទាំងពួងនៅខាងមុខ ត្រូវតែខ្លួនយើងទទួលយកបំណោចរបស់កម្មណាមួយដែលខ្លួនបានធ្វើដោយខ្លួនឯង (គឺថា ចូរអ្នកធ្វើការដល់អ្នកដទៃចំពោះការណាដែលអ្នកចង់ឲ្យគេធ្វើដល់ខ្លួនអ្នក) ។ ពាក្យនេះជាទុកមួយយ៉ាងធំដែរ ដែលគួរនាំយកមកប្រើក្នុងការលុបលាងហេតុវិវាទទាស់ទែងគ្នានឹងសង្គ្រាមផ្សេងៗបាន ។ ដម្បូន្មាននេះទុកជាបញ្ញាប់សម្រាប់មនុស្សម្នាក់ៗ ឬជាតិនីមួយៗ លែងប្រព្រឹត្តិបទអាក្រក់ លែងដេរប្រទេចផ្តាសាអ្នកដទៃ

ដែលមានសេចក្ដីសុខក្សេមក្សាន្តមានសន្តិភាព សឹងគ្រប់ៗជាតិត្រូវការ ប្រាថ្នា តែឥតបានធ្វើការអ្វីឲ្យបានសន្តិភាពនោះសោះ ។

មិនមែនដោយការបង្កើនគ្រឿងអាវុធយុទ្ធភណ្ឌស្មុគស្មាញនោះទេ ដែលនាំយកមកប្រើជាវិធីសន្តិភាពនេះៗ សូម្បីការជួយជ្រោមជ្រែងបាន: ដែលនៅទន់ទាប នឹងប្រើត្រឹមយុត្តិធម៌យ៉ាងពុំបានទេ ពោលគឺមានមេត្តា- ចិត្តប្រកបផង សូម្បីតែហេតុដោយហោចទៅនឹងប្រើត្រឹមសេចក្ដីយុត្តិធម៌ ក៏ពុំល្មមគ្រប់គ្រាន់ដែរ ។ ប្រសិនបើនានាជាតិនៅតែមានសង្គ្រាមទៅ លើកងទ័ពដែលមានអាវុធយុទ្ធភណ្ឌយ៉ាងសំបើមដូច្នោះ ជាតិអស់នោះនឹង មិនផុតពីសេចក្ដីក្ដៅក្រហាយដែលចងរួបរឹតខ្លួនឯងឡើយ ។ រឿងនេះត្រូវ តែអ្នកប្រាជ្ញបាស់ៗរាល់គ្នារិះរកវិធីកែប្រែសេចក្ដីប្រព្រឹត្តរបស់សាកលពិ- ភពលោកនេះជាថ្មី ដើម្បីដាក់លក្ខណៈយុត្តិធម៌ទឹងបង្កើតឲ្យមានរបៀបល្អ ឡើង នឹងរៀបចំឲ្យជាទីគាប់ចិត្តទូទៅ ។

តាមដោយពិត លទ្ធិដែលនិយាយពីចិត្តវិជ្ជាតែងសំដែងថា បណ្ដា ហេតុកេទផ្សេងៗក្នុងលោកនេះ សុទ្ធតែកើតមកពីជីវិតទ្រិយខាងក្នុងនឹង និស្ស័យសន្ដានខាងក្នុងចិត្តនៃមនុស្សទាំងឡាយទូទៅ ហេតុនេះបាន ជាពោលថា គ្រឿងបគ្រឹក្សាសីលធម៌នឹងចិត្តវិជ្ជា រមែងមានអានុភាពជាប់នៅ ក្នុងផ្លូវខែពង្សាវតារ (នានាជាតិ) ជាដរាបមក ។ ហេតុនេះបានជាបាក់ង-

សែស និងអង់គ្លេស កាលពីឆ្នាំ ១៩១៤ នគរទាំងពីរដែលមានដំឡៃនៃសីល-
ធម៌និងចិត្តវិជ្ជា នៅលើប្រទេសអាល្លឺម៉ង់ ទើបមានជ័យជំនះដែលមិនគួរ
ឈ្នះ នៅខេត្តម៉ារ៉ន៍ ។

ហេតុនេះ ប្រសិនបើយើងប្រាថ្នាសន្តិភាព ត្រូវតែគិតកសាងសមា-
គមសម្រាប់មនុស្សដ៏សមរម្យ ហើយការសន្សំអប់រំកម្លាំងសីលធម៌និង
វិធីប្រតិបត្តិខាងផ្លូវចិត្តឡើង ។ កងទ័ពដែកខាងចិត្តវិញ្ញាណនេះនាំឲ្យ
ចំរើនសុខសន្តិភាពឡើងរាល់ៗថ្ងៃ ហើយសន្តិភាពនេះមានអំណាចតាំង
នៅចិតថេរចេរកាល តាំងនៅលើទីដ៏រឹងប៉ឹងបំផុត ។ ជ័យជំនះអស់នេះជា
ជ័យជំនះយ៉ាងជាប់ស្រេចរបស់សីលធម៌និងមេត្តាចិត្តរបស់មនុស្ស ទើប
អាចកំចាត់បង់នូវអត្តទិដ្ឋិចេញបាន តែគោងនាំយកមកប្រើក្នុងវង្សត្រកូល
រហូតដល់សាលាបង្រៀន ។ ឥឡូវនេះ នៅមិនទាន់មានសំណាក់សិក្សា
សីលធម៌នូវទៅនៅឡើយ បើចាត់ឲ្យមានការសិក្សាតាមវិធនេះដល់នា-
នាជាតិនូវទៅ សេចក្តីចំរើនទឹងកើតឡើងជាប្រាកដមិនខាន ប្រសើរជាង
វិធីរបស់អត្តទិដ្ឋិដែលដំកល់នៅលើជើងថ្កានោះឯង ក្នុងសម័យឥឡូវ ដំឡៃ
នៃសីលធម៌លេតខ្សត់ខ្សោយអស់ទៅ នាំឲ្យអស់សង្ឃឹមក្នុងផ្លូវសន្តិភាព
ព្រមទាំងវប្បធម៌ បើទុកជាខំប្រឹងប្រែងស្វែងរកដោយសតិបញ្ញាយ៉ាងល្អិត
សុខុមយ៉ាងណា ក៏នៅតែកម្រនឹងធ្វើឲ្យកើតចំរើនឡើងបាន ។

ប្រសិនបើមានគ្រោងការបង្រៀនប្រទេសផ្សេងៗឲ្យទទួលប្រតិ-
បត្តិតាមវិធីការនេះ ដែលជាវិធីការមួយដែលអាចដឹកនាំនាគ្រប្រទេសឲ្យ
មានសន្តិភាពដ៏រឹងប៉ឹងតាំងនៅក្នុងដួងចិត្តរបស់ប្រជាជនតគ្រៅខាងមុខ ដ្ឋត
ជ្រាបចូលគ្រៅក្នុងសតិសម្បជញ្ញៈ ក្នុងការណ៍យកចិត្តនាគ្ន ក្នុងសមាគម
សុទ្ធតែមានសីលធម៌ល្អតាំងអស់ ទើបមនុស្សជាតិសព្វថ្ងៃនេះដកខ្លួនថយ
ចេញចាកអន្ទាយដែលមាននៅសព្វថ្ងៃនេះបាន ។

យើងត្រូវតែជាស់ចិត្តគំនិតរបស់យើងឲ្យព្ងាកទំកដល់ការណ៍យកចិត្ត
ផ្សេងៗដែលជាប់ទាក់ទងគ្រៅនឹងអ្នកដទៃ ហើយពិចារណារិះរកហេតុផល
ដែលនាំឲ្យទាស់ទែងខ្វែងគំនិតគ្ន ។ អារ្យធម៌ពិតប្រាកដនោះជារបស់
មានជំនឿថ្ងៃថ្ងូរណ្ណាស់ បើប្រតិទ្ធប់ជាតថ្ងៃគ្រៅវិញ ក៏រមែងក្លាយ
គ្រៅជាចម្ការ៖ត្រៃមួយយ៉ាងធំតែម្ត្ត ។

តាមធម្មតា យុត្តិធម៌របស់មនុស្សនឹងជុះគ្ងៀងក្នុងដួងចិត្តរបស់មនុស្ស
នេះលុះតែចិត្តវិជ្ជាមានអានុភាពក្លាយពន្ធ៌ស្ងៀងត្រ្ងាងត្រ្ងាត ទើប
ឃ្លាតចេញពីសត្រូវធំតាំងពីរគឺ ១ ទ្ធេទ្ធិដ្ឋ (លទ្ធិមិនជឿស្ថានសួគ៌-នរក)១
អត្ថទ្ធិដ្ឋ (លទ្ធិយល់តែប្រយោជន៍ខ្លួន-ពួកខ្លួន-ជាតិខ្លួន) ១ ។ ដោយ
ហេតុសេចក្ដីខ្វាក់រវ្ងើងរបស់លទ្ធិ ម៉ាតេរីយ៉ាលិស្ម៌ ទើបធ្វើឲ្យបាត់មេត្ត្ចិត្ត
តាមផ្លូវចិត្តវិជ្ជារបស់បណ្ដាសត្វដែលមានជីវិតនៅក្នុងលោកនេះ ត្រ្ងមកដ

ចិត្តវិជ្ជានេះ បើបានរៀបចំចាត់បង្កើតឲ្យមានរបៀបមាំមួនហើយ នឹងនាំមកនូវសេចក្តីសុខ-ចំរើន-សេចក្តីស្មិទ្ធស្មេហានឹងសតិបញ្ញាព្រមទាំងសីល-ធម៌ដ៏ល្អផង ។

កាលបើបណ្តុះចិត្តវិជ្ជានឹងសីលធម៌ក្នុងតំនិតរបស់ប្រជាជនទូទៅជូចពោលមកនេះ នឹងនាំមកនូវសន្តិភាពក្នុងលោកព្រមទាំងយុត្តិធម៌ដ៏ទៀងទាត់ជាច់ស្រេចផងមិនខាន ។

ពង្សាវតារក្រិក

(តមក)

លុះដល់មកក្នុង ព. ស. ១២២ ពួកអាថែន្សនឹងស្ប៉ាតក៏នាំគ្នាធ្វើសញ្ញាស្ងប់សឹកសង្គ្រាមដោយព្រមព្រៀងគ្នាថា ត្រូវទាំងពីរខាងប្រគល់ទឹកដីដែលខ្លួនវាយបាននោះទៅម្ចាស់ដើមរៀងខ្លួនវិញ ទើបមើលឃើញថា សង្គ្រាមគ្រានេះមិនមានខាងណាចាញ់ខាងណាឈ្នះទេ ប្រហែលការល្បងថ្វីដៃគ្នាមើលប៉ុណ្ណោះអស់វេលា ១០ ឆ្នាំ ។

ក្នុងភាគទី ២ នេះ និយាយពីបុរសម្នាក់ឈ្មោះ អ័លស៊ីប៊ីយ៉ាដ៍ ជាក្មួយរបស់ប៉េរីក្លេស ជាអ្នកមានរូបឆោមល្អនិងមានទ្រព្យធនស្ដុកស្ដម្ភរបស់ក្រិកក្នុងគ្រានោះ ថែមទាំងជាអ្នកឆ្លៀវឆ្លាតប៉ិននិយាយផង ទើបធ្វើឲ្យប្រជាជនដែលល្ងង់ខ្លៅស្រឡាញ់ពេញចិត្តជាច្រើន ៗ បុរសនេះគិតការធំហួសពេក និយាយពន្យល់ដឹកនាំប្រជាជនអាថែន្សឲ្យជឿស៊ប់ថា ប្រសិនបើលើកទ័ពទៅវាយពួកដូរិយ៉ង្សនៅកោះស៊ីស៊ីលបាន ទើបអាថែន្សមានអំណាចតាមផ្លូវសមុទ្របានគ្រប់ភាគ ស្រុកស្ប៉ាតនោះក៏ហាក់ដូចពងមាន់នៅក្នុងកណ្ដាប់ដៃ ៗ យើងបានដឹងហើយថា មនុស្សដែលមានអំណាចជាងគេ គឺមនុស្សដែលនិយាយពូកែជាងគេ ហេតុនេះបានជាប្រជាជនអាថែន្សប្រគល់ឲ្យអ័លស៊ីប៊ីយ៉ាដ៍ជាមេទ័ពធំនាំទូកចម្បាំង ១៣៤ នឹងទាហាន ១០.០០០ នាក់ ទៅធ្វើការតាមដែលគិតទុកនោះ

ដោយជឿថាមុខជាបានសម្រេចជាពិតប្រាកដមិនខាន ។ អ័លស៊ីប៊ីយ៉ាទ៍ចេញទៅមិនទាន់យូរប៉ុន្មាន ស្រាប់តែត្រូវគេចោទថាជាអ្នកមើលងាយទេវរូបដែលជាទីគោរពដែលជាកំហុសយ៉ាងធំមួយក្នុងគ្រានោះ ក៏និកខ្លាចពួកអាថែនស្រាប់ខ្លួនទៅប្រហារជីវិត ទើបភៀសទៅនៅជាមួយនឹងពួកស្ប៉ាត ។ និស្សាសជាបក្ខពួករបស់អ័លស៊ីប៊ីយ៉ាទ៍ ទទួលធ្វើការនាំទ័ពចេញទៅច្បាំងតាមគ្រោងការនោះ តែត្រូវពួកស្ប៉ាតវាយខ្ទេចខ្ទី ទូកចម្បាំងក៏វិនាសហិនហោចអស់ទៅ ពួកទាហានត្រូវចាប់សម្លាប់ទីងត្រូវជាឈ្លើយសឹកស្ទើរតែមិនមានសល់ត្រឡប់មកអាថែនម្នាក់ នេះចាត់ជាការបរាជ័យគ្រាដំបូងរបស់ពួកអាថែន ហើយជាបរាជ័យដែលនាំមកនូវសេចក្ដីវិនាសដល់ស្រុកអាថែនទាំងមូលផង ។

ក្នុងកាលទី ៣ ពួកស្ប៉ាតបានបបួលដឹកនាំពួកស្រុកដែលនិយមវិធីគ្រប់គ្រងដោយមន្ត្រីនោះមកចូលរួមជាមួយគ្នាផង ហើយខណៈនេះពួកស្ប៉ាតដឹងខ្លួនច្បាស់ថា ការដែលនឹងប្រាបប្រាមស្រុកអាថែនឲ្យបានសម្រេចនោះលុះតែខ្លួនមានកងទ័ពជើងទឹកពូកែផង តាមគំនិតនេះហើយទើបពួកស្ប៉ាតខំកសាងកងទ័ពជើងទឹកឲ្យមានកំឡាំងមាំម៉ាត់ឡើង ហើយកងទ័ពជើងទឹកទាំងពីរខាង ក៏បានច្បាំងតទល់គ្នាយ៉ាងធំសំបើម នៅទិសខាងកើតឆៀងខាងជើងនៃសមុទ្រអេសេ ។ ការដែលពួកស្ប៉ាតខំប្រឹងលើកទ័ពជើងទឹកមកដល់ទីនោះ ដោយបំណងនឹងកាត់ផ្លូវបញ្ជូនស្បៀង

ដែលពួកអាថែន្សបានទទួលពីស្រុកត្រាស់ គ្រោងការណ៍នេះ ស្ប៉ាតបានចាប់ផ្តើមតតាំងពីផ្តើមច្បាំងគ្នា ។ ក្នុងខណៈនោះ ពួកប៉ែក្យ៉ូដែលចង់ចិត្តអាយាជនធំនៃស្រុកអាថែន្សតាំងអំពីដើមស្រាប់នោះ ក៏ដាក់មកចងស្ពានមេត្រីនឹងពួកស្ប៉ាត បានឲ្យប្រាក់ការជួយក្នុងចម្បាំងរបស់ស្ប៉ាត ។ មេទ័ពស្ប៉ាតម្នាក់ឈ្មោះ លីសង់ដ្រ ដ៏ បានចាត់ការវាយទ-ណាយកងទ័ពអាថែន្សចេញបានហើយយឹតព័ទ្ធស្រុកអាថែន្ស នៅទីបំផុតស្រុកអាថែន្សមានអន្តរាយដល់ទៅ ២ ផ្លូវ គឺខាងក្រៅស្រុក សឹកសត្រូវព័ទ្ធបាន ខាងក្នុងស្រុកកើតទុរ្ភិក្សអត់ថ្នាយ ហើយពួកនាហ្ម៉ូនមន្ត្រីក៏ខ្ចាំគ្នាក្បត់ទឹងស្រុកទេសរបស់ខ្លួនផង ទើបដល់ទីការបរាជ័យយ៉ាងធ្ងន់ធ្ងរលើង ។ សង្គ្រាមគ្រានេះបានផុតចប់ក្នុង ព. ស. ១៣៩ (មុន គ. ស. ៤០៤) ។ ផលនៃសឹកសង្គ្រាមគ្រានេះ អាថែន្សត្រូវប្រគល់ស្រុកចំណុះរបស់ខ្លួនឲ្យស្ប៉ាតជាចំនួនច្រើន ហើយអំណាចរបស់អាថែន្សក៏ផុតរលត់ដោយប្រការដូច្នេះឯង ។

សង្គ្រាមគ្រានេះ បានធ្វើដោយអាការសាហាវជាបំផុត តាំងពីចាប់ផ្តើមច្បាំងគ្នា ពួកស្ប៉ាតចាប់ឈ្លើយបាន ក៏ច្រចាប់កសម្លាប់ឥតមេត្តាប្រ-ណី លីសង់ដ្រមេទ័ពស្ប៉ាតគ្រាយនេះបានបង្ហាប់ឲ្យទាហានខ្លួនច្រចាប់កពួកទាហានអាថែន្សដល់ទៅ ៣០០០ នាក់ ឥតមានញ្ញើតរ៉ាកើបចន្ទ្ធ-ឡើយ ។ ពួកស្ប៉ាតដែលជាអ្នកមានទិស្សយសន្ធានមោះមុតយោរយៅ

(មានត)

ប្រជុំពាក្យកាព្យ

ភាគទី ៤

ឈស់ឃុនសុីមនោម័យ

(មានត)

ក្តីស្នេហ៍នេះនឹងប្រៀបឧបមា
បីដូចមច្ឆាពឹងសាគរ
បើទឹកត្រជាក់ស្ង័ត្រស្នោះសារ
នឹងតទល់ផុតលេតជន្ម ។

បើទឹកនោះក្តៅពុំត្រជាក់
សត្វដែលសំណាក់កើតទុក្ខធ្ងន់
មិនមានសប្បាយកាយទោរទន់
ស្រពោនស្រពន់គ្រប់វេលា ។

សេចក្តីសំរើបមិនដែលស្រស់
បេះតែក្រៀមក្រស់ក្រំគ្រប់គ្រា
ចួបក្រហាក់បានក្សាន្តទយា
នេះថែមវេទនាជាចង្រ្តួយ ។

ប្រាសប្រាណដេកទៅតែឯកា
ឈោងចាប់ក្រមាយកមកហើយ
លាតលាដណ្តប់ទុក្ខគ្រាន់ស្បើយ
ក្លិនស្រីនៅឡើយចងចាំបាន ។

មិនមានប្រែប្រួលចំឡែកសោះ
ចំពោះជាក្លិនកែវកល្យាណ

ថើបហើយសើរ្យ៉ាយទុក្ខពីកន្ត្រ(ហ)ណ
ចាប់ចាន់ផ្ទ(ហ)ចាន់ការ៉ាន់ថើបទ(ៀ)ត ។
ក(ៀ)ងកំ(ង)ការ(ំ)ងទុក្ខថ(ៃ)មជាថ្ម
ទ(ឹ)ក(ថ)ម(ៃ)ទ(ូ)ងរ(ៃ)ងរ(ំ)ងប(ង)ន(ៃ)ត
ទុ(ក)ម(ួ)យ(ដ)ល(ប)ង(ំ)ឈ(ូ)ប(ន)ត(ៀ)ត
ម(ាន)ទ(ៀ)ត(ឲ)ថ(ៃ)ឈ(ើ)ចិ(ត)ត(ផ)្ស ។
ក(ៃ)ម(ើ)យ(ខ)ួ(ន)ប(ង)ពេ(ញ)ហ(ៅ)ទ(ុ)ស
ដ(ោ)យ(ស)ារ(ជ)ា(ប)្រ(ុ)ស(ណ)ោ(ត)ណ(ា)
(ត)ន(ំ)ណ(ះ)ន(ះ)ត(ាម)ដ(ែ) ម(ត)ា
ពេ(ស)ាទ(ុ)ពេ(ស)ប(ណ)ីម(ើ)យ ។
អ(ក)ក(ពោ)ម(យ)ង(ំ)អ(ង)ម(ត)ត(ត)
ក(ៀ)ង(ក)ាយ(ក)ាយ(ត)េ(ទ)ក(ង)ចិ(ត)ា
ក(ាល)ដ(ើ)ម(ថ)ាស(ូ)ប(ូ)ដ(ី)
ន(ឹ)ក(ថ)ាស(ូ)ស(ា)ប(់)ដ(ូ)ចអ(ន)ិ(ទ)្ធ ។
ម(ិ)ន(ខ)ាចហ(ៅ)ក(ូ)ង(ច)ម(យ)ក(ូ)
ន(េ)ះ(ពេ)ញ(ហ)ៅ(ថ)ាក(ូ)ចិ(ត)ម(ុ)ត
ខ(ួ)ន(យ)ើ(ង)ៗ(ប)្រ(ៀ)ប(ដ)ូ(ច)អ(ន)ិ(ទ)្ធ
ខ(ួ)ន(ប)ួ(ន)ស(ុ)ទ(ដ)ូ(ច)ត(ុ)ស(ា) ។

សេឡាញ់ជ្រាកដដូចពាក្យស្ត្ី
មិនប្រែចិត្តឱ្ធដូចកន្សា
នឹងទៀងជ្រាកដដូចសញ្ញា
នឹកថាមិនឲ្យកេរ្តឹអប្រីយ៍ ។

ឱ្ធនយើងជាប្រុសមែនពិតហើយ
កែវអើយតែចិត្តដូចកង្រី
មិនឲ្យមានពីរទេប្អូនស្រី
សេចក្តីដូចប្អូនផ្តាំបងថា ។

ឲ្យឱរក្សាសីលសីត្យញាណ
កុំមានសេចក្តីនឹកបេក្ខា
យើងសោតយើងចាំដូចសញ្ញា
កនិដ្ឋាបែរចិត្តពុំទៀងត្រង់ ។

ឧះឧព្រះសុរិយាអស្តង្គត
ទៀបជុតចាំងជ្រុងសុមេរា
បំព្រាងរស្មីនៅភ្ជឿថ្ថា
សព្វសត្វសកុណាវិលទ្រនំ ។

ត្រឲ្យប់ងងឹតសព្វទិសទី
ទៀបទ្ធងកេរិព្រលប់ធំ

សកុណីចាកវៃពៃវិលទ្រនំ
កមរាចាកបង់ក្រែបកេសរ ។

ចតុប្បាទទ្វេជាទចាកវាលបឹង
កមរាទ្រហឹងសំឡេងខ្ជរ
តម្រែកត្រេកត្រិះហើយសាទរ
សត្វវាត្រេកអរគ្ជរសប្បាយ ។

តារាត្រោងប្រុះធ្លុះវេហាស៍
អស់ទាំងមនុស្សម្នាសុខក្នុងកាយ
ឃ្លាតគ្ជប្ជបគ្ជមិនមានធ្លាយ
ត្រែជ្រាណាឯកាយឯកោនៅ ។

កំព្រាវេទនាសែនរំខាន
ហើយថ្មែមទាំងមានសេចក្តីក្តៅ
ម្រាំងមួយរៀមព្ជួយនឹកជល់ញៅ
ឧថ្ងើរនេះនៅឬទៅណា ។

ឬមួយឬននៅក្នុងដំណេក
ទល់ទុក្ខវិវេកឧបេក្ខា
នឹករៀមឬស្ទៀមឬបរចារ
ឬមាននរណានាំនិយាយ ។

(មានតទៅទៀត)

អនាមយតាថា

១. ស.

ជាអ្នកប្រែនិងរៀបរៀង

(តមក)

អំពីយុទ្ធវិធីរបស់រាងកាយ

កាលបើមានមេរោគចូលមកកាន់រាងកាយយើងៗ បានចាត់ការតស្ទូ ទប់ទល់ដោយវិធីដូច្នេះ :

១) ធ្វើកំដៅឲ្យកើតឡើងក្នុងរាងកាយ ដែលយើងហៅថា ត្រុន មានអាការធ្ងន់-ស្រាល ស្រេចតែមេរោគនោះសាហាវឬមិនសាហាវ ៗ កំដៅនេះមានប្រយោជន៍សម្រាប់សម្ងាប់មេរោគ ឬធ្វើឲ្យខ្សោយថយកំឡាំងចុះទៅ ព្រោះមេរោគផ្សេងៗដែលចូលមកប្រទូសរ៉ាយក្នុងរាងកាយយើងរមែងមានអំណាចប្រើនក្នុងរវលាដែលរាងកាយយើងមានកំដៅអ៊ុនៗ តាមធម្មតាប្រសិនបើកំដៅនេះក្តៅហួសកំរិតនេះហើយមេរោគនោះក៏ទ្រាំកំដៅមិនបាន រមែងដល់នូវសេចក្តីវិនាសទៅ មានទំនងដូចជាយើងតាំងកាំ-ក្ងើងធំសម្រាប់បាញ់យន្តហោះដែលហោះមកទម្ងាប់ត្រាប់ចែកតាមផ្ទូវអាកាស ហើយបង្កប់ត្រាប់ចែក (មីន) ក្នុងទឹក ដើម្បីបង្ការកម៉ាល់ចម្បាំងរបស់សត្រូវដញ្ជូនទាហានមកឡើងគោកបាន បិទផ្ទូវដើរទ័ពរបស់សត្រូវត្រប់ច្រក ហើយតាំងកាំក្ងើងធំប្រចាំប៉មសំទាន់ៗ ជាដើម នេះជាការប្រុង

ត្រៀមខ្លួនរបស់រាងកាយយើងក្នុងថ្នាក់ដំបូង ហេតុនេះ បានជារោគដោយច្រើន មានអាការក្តៅជាដំបូង ហើយអាការឯទៀតៗកើតឡើងជាលំដាប់ បើកំដៅនេះមិនហួសពីកំរិត ៤០ ឬមានកំដៅល្មមខ្លួនយើងទ្រាំទ្របាន យើងក៏មិនបាច់ប្រើថ្នាំអ្វីនិមួយទេ ទុកឲ្យកំដៅនោះថយចុះមកឯងតាមធម្មតា វៀរលែងតែពិនិត្យទៅឃើញថាខានប្រើថ្នាំពុំបាន ដូចជាជម្ងឺដេកមិនលក់ ទៅជាមមើមមាយខុសប្រក្រតី ។ល។ កំដៅមានប្រយោជន៍ច្រើនដល់រាងកាយក្នុងការតស៊ូទឹងមេរោគ ឬមេជម្ងឺ ។

២) កេណ្ឌទាហានឲ្យចូលប្រចាំក្រុមកងសម្រាប់ធ្វើការតទល់នឹងពួកសត្រូវ គឺតួលោហិតស ក្នុងលោហិតស ១ដំណក់ មានតួលោហិតក្រហមប្រមាណ ៤ លានតួ ឯតួលោហិតសនេះមានប្រមាណ ៨ ពាន់តួ មានច្រើនយ៉ាងច្រើនពួក មានមុខក្រសួងផ្សេងៗគ្នា មានទាហានថ្មើជើងប្រមាណ ៧០ % ក្រៅពីនេះជាទាហានកាំភ្លើងធំ ទាហានសេះ ទាហានជាដើម ។ ឯពួកលោហិតក្រហមនោះ មានមុខក្រសួងដឹកជញ្ជូនស្បៀងអាហារជាកំឡាំងក្នុងចម្បាំង កាលបើកើតសឹកសង្គ្រាមដល់ខ្លួនយើងឡើងហើយ តួលោហិតសក៏កើតឡើងច្រើនណាស់ដែរ ក្នុងលោហិតមួយដំណក់ អាចមានតួលោហិតសទាំងហ្មឺនទាំងសែន. គឺថារាងកាយយើងកេណ្ឌទាហានបន្ថែម ពួកដែលបម្រុងទុកទាំងប៉ុន្មានក៏ហៅប្រជុំឲ្យចូលមកប្រចាំការទាំងអស់ ។

ក្នុងកងកាយមនុស្សធំហើយដែលមានទម្ងន់ដល់ទៅ ៦០ គីឡូក្រាម មានតួលោហិតប្រមាណ ៣ លានដំណក់ ក្នុងមួយដំណក់មានពលចម្លាំងប្រមាណ ៨ ពាន់ ពលដួយចម្លាំងមានប្រមាណ ៤ លាន សូមឲ្យគិតលេខមើលចុះ បើលោហិត ៣ លានដំណក់ តើត្រូវមានពាហានជាចំនួនប៉ុន្មានទៅ ? ឯម្ចាស់ត្រីនោះក៏មានចំនួនច្រើនលើសលន់គណនាណាស់ដែរ ដូច្នេះតើគួរយើងហៅថា មហាយុទ្ធសង្ក្រាមបានឬទេ ? ។

ឯមហាយុទ្ធសង្ក្រាមលោក ក្នុងគ្រាដែលកន្ទ្រងមកហើយនោះមានពលចម្លាំងទាំងសងខាងយ៉ាងច្រើនត្រឹម ១០ លានពាក់ប៉ុណ្ណោះ ទើបយើញថា មហាសង្ក្រាមក្នុងកងកាយយើងធំជាងឆ្ងាយណាស់ ។

៣) កាលបើបានប្រជុំគ្រមកម្លាំងព្រមមូលគ្នាហើយ ទើបកងកាយបញ្ជូនតួលោហិតសមកព័ទ្ធទ្បោមមេរោគដោយដុំវិញ នេះដូចជាការបញ្ជូនពាហានទៅតទល់នឹងពួកខ្មាំងសត្រូវ តួលោហិតចំពួកខ្លះស្ទុះទៅទាំស៊ីមេរោគអស់នោះពាល់ត្រូវស្លាប់អស់ទៅក៏មាន ។ បើបែរជាតស៊ូនឹងមេរោគពុំបានឬត្រូវថ្នាំបំពុលស្លាប់ ក៏ក្លាយទៅជាខ្ទុះឡើង ខ្ទុះព័ណ្ណសនោះក៏គឺតួលោហិតសនឹងសាច់ស្បែកដែលខូចខាតខ្ទេចខ្ទីអស់ទៅហ្នឹងឯង ។ តាមធម្មតាតួលោហិតស ១ អាចតស៊ូនឹងមេរោគបាន ១០ តួ ។

(នៅមានត)

រឿងព្រេងខ្មែរ — រឿងអាឡេវ ទី២

(តមក)

ឯកូនប្រពន្ធដែលកាន់ដំបងព្រនង់ចាំនៅមាត់ទ្វារ ឃើញប្ដីគេចូលមកក្នុងផ្ទះ គិតស្មានថាជាព្រាយក្បាលត្រដោលមែន ក៏ពីតវាយទាល់តែដួលសន្លប់ខ្វះរបួសពិការខ្វះ លុះក្រោយមកទើបបានដឹងថាប្ដីជាអាពុកខ្លួន ហើយនិយាយដំណើរប្រាប់ប្ដីសព្វគ្រប់ ៗ ពួកចោរទាំង ៥០០ ខឹងនឹងអាឡេវខ្លាំងណាស់តែមិនដឹងគិតធ្វើដូចម្ដេច ព្រោះខ្លួនត្រូវដំបងជាដំណាំទាំងអស់គ្នាហើយមិនដឹងជាអាឡេវនៅឯណា ៗ វេលានោះ អាឡេវនៅចាំស្ដាប់ប្រពន្ធកូនចោរវាយប្ដីខ្លួន ដល់ព្រុមាត់ស្រែកទ្រហឹងពេញពាសទាំងស្រុក ក៏បើកសំពៅត្រឡប់ទៅស្រុកប្រពន្ធវិញ លុះទៅដល់ហើយអាឡេវនឹងប្រពន្ធឡើងទៅរកជីដូន បានជួបនឹងជីដូនក៏សំពះសូមទោស ហើយប្រគល់របស់ទ្រព្យក្នុងសំពៅទាំងប៉ុន្មានៗជូនជីដូនទាំងអស់ ៗ ឯជីដូនបានឃើញទ្រព្យសម្បត្តិអាឡេវពេញសំពៅក៏បាត់ខឹង បែរជាស្រឡាញ់អាឡេវពប់អានជាចៅប្រសាមែនទែន ៗ អាឡេវរៀបសង់ផ្ទះលោះខ្ញុំកំដរឲ្យបំរើជីដូនក្មេកនឹងប្រពន្ធពាសពេញក្នុងផ្ទះ លុះនៅយូរបន្តិចមកក៏លាជីដូននឹងប្រពន្ធទៅសួរម្ដាយអាពុកវា ជីដូនក្មេកផ្ដាំថាបើចៅទៅកុំនៅយូរពេក ឆាប់ត្រឡប់មករកជីដូនវិញ ដ្បិតសព្វថ្ងៃនេះកំព្រាឥតមានអ្នកឯណាជាទីពឹងទេ ៗ

ឯប្រពន្ធអាឡេវ បង់តាមអាឡេវទៅដែរ ហើយនិយាយថាខ្ញុំចង់ទៅជាមួយនឹងអ្នកឲ្យស្គាល់ម៉ែឪបងប្អូនញាតិសន្តានស្រុកទេសអ្នក មួយទៀតខ្ញុំមិនចង់ឲ្យឃ្លាតឆ្ងាយពីអ្នកទេ ដ្បិតថាស្រីប្តីទៅឆ្ងាយហើយកម្រនឹងទុកដាក់រក្សាខ្លួនណាស់ អ្នកជនគេតែងនិន្ទាថាដូចជាស្រីមេម៉ាយចំណាយមាត់គេ ហេតុដូច្នេះបានជាខ្ញុំមិនចង់នៅ ចង់ទៅតាមអ្នកជាប្តី ។ អាឡេវឆ្លើយឡើងថា នាងអើយ បងចង់បាននាងទៅជាមួយដែរ ប៉ុន្តែអាណិតជីដូនដ្បិតគាត់ចាស់ជរាណាស់ហើយ ក្រែងឈឺចាប់យប់ថ្ងៃ គ្មាននរណាថែទាំបីបមរក្សាដុសថ្នាំចាំជម្ងឺ នឹងទុកចិត្តលើមនុស្សម្នាខ្ញុំក៏ជឿមិនបានទេ ដូចកាលយើងនាំគ្នាទៅនោះ គាត់សន្ទឹកសន្ធៃឈឺរាំរៃស្គាំងស្គមទើបនឹងបានគ្រាន់បើ ឥឡូវនេះបើយើងទៅចោលគាត់ទៀត គាត់នឹងឈឺស្លាប់ពុំខានឡើយ ពីមុនបានជាខុសឆ្គាយម្តងរួចទៅហើយ ឥឡូវនេះយើងគិតកុំឲ្យខុសឆ្គាយទៀត ។ ឯប្រពន្ធឮប្តីស្រដីថាដូច្នោះហើយ នឹកអាណិតជីដូន ព្រមឲ្យប្តីទៅ ទើបរៀបស្បៀងស៊ីរៀងតាមផ្លូវសព្វគ្រប់ហើយសួរប្តីថា អ្នកនឹងយកមនុស្សម្នាទេះសេះឡើទៅប៉ុន្មាន អាឡេវឆ្លើយថាបងមិនយកទៅទេ បងទៅតែម្នាក់ឯង ។ ឯគំនិតអាឡេវបានជាមិនចង់យកមនុស្សម្នាទៅ ពីព្រោះគិតចង់បានប្រពន្ធច្រើន បើនឹងយកមនុស្សតាមក្រែងគេដឹងថាខ្លួនមានប្រពន្ធហើយ នឹងទៅដណ្តឹងកូនគេទៀតក្រែង

(នៅមានត)